Commonwealth of Massachusetts
Executive Office of Health and Human Services
Executive Office of Elder Affairs

# សិទ្ធិរបស់អ្នកដើម្បីសុំតវ៉ា ទៅការិយាល័យប្រតិបត្តិការ កិច្ចការចាស់ទុំ

បើអ្នកជឿងថាការសំរេចពីការពិនិត្យមើលឡើងវិញនៃ លទ្ធភាពទទួលចំណុចការបំរើជរាវ័យ [Aging Services Access Point (ASAP)] មិនបានសំអាងលើ ដំណើរហេតុដោយត្រឹមត្រូវទេ ឬពុំបានធ្វើឲ្យស្របតាមបញ្ញត្តិ និងក្រិត្យក្រមជាធរមានទេ អ្នកអាចសុំតវ៉ាទៅការិយាល័យប្រតិបត្តិការ កិច្ចការចាស់ទុំ (Executive Office of Elder Affairs) បាន ។

## សិទ្ធិរបស់អ្នកនៅក្រោមច្បាប់លេខ 651 នៃរដ្ឋម៉ាស្សាជូសេត បញ្ញត្តិលេខ 1.00 et seq ។

- អ្នកមានសិទ្ធិឲ្យបានគេស្តាប់រឿងហេតុ នៅឯសវនាការ(ដំណើរស្តាប់រឿងហេតុ) កិច្ចការចាស់ទុំ ។
- អ្នកអាចត្រួតពិនិត្យ និងថតចំឡង (ចំណាយប្រាក់កាសខ្លួនឯង) នូវសេចក្តីទាំងឡាយនៃសំណុំរឿងរបស់អ្នក នៅពេលណាក៏បាន ។
- អ្នកអាចជ្រើសរើសមនុស្សម្នាក់ ឲ្យធ្វើជាតំណាងអ្នកនៅឯសវនាការ ។
- អ្នកអាចបញ្ជូនសំបុត្រស្នាម (ច្បាប់ចំឡងនឹងត្រូវឲ្យទៅ ASAP)។
- អ្នកអាចឲ្យសាក្សីនិយាយជំនួសអ្នក នៅឯសវនាការ ។
- អ្នកអាចស្នើថា សវនាការគប្បីធ្វើតាមទូរស័ព្ទ ឬធ្វើដោយផ្ទាល់មុខ។

**វិធីសុំតវ៉ា** – សវនាការគឺជាឱកាសជាផ្លូវការមួយ ដើម្បីថ្លែងប្រាប់ពីមូលហេតុដែលអ្នកជឿថាការសំរេចដោយ ASAP បានធ្វើឡើងដោយមិនត្រឹមត្រូវ ។ សវនាការគឺធ្វើ ឡើងតាមរយៈការប្រជុំតាមទូរស័ព្ទ ឬធ្វើនៅឯការិយាល័យកិច្ចការចាស់ទុំ ។ នាយកសវនាការ ធ្វើសវនាការទាំងអស់ និងសវនាការដែលបានថតសំឡេងទាំងអស់ ។

សមាជិកបុគ្គលិក ASAP ម្នាក់ ឬលើសពីម្នាក់ នឹងមានមុខនៅទីនោះ ដើម្បីពន្យល់ពីមូលហេតុដែលគេបានសំរេច ពីការដែលអ្នកកំពុងតែសុំតវ៉ា និងពន្យល់ពីរបៀបត្រឹម ត្រូវនៅក្រោមបញ្ញត្តិ និងក្រិត្យក្រម នៅពេលបច្ចុប្បន្ននេះ ។ នៅមុនពេលសវនាការ ច្បាប់ចំឡងនៃសំបុត្រស្នាមទាំងប៉ុន្មានដែល ASAP នឹងប្រើនៅពេលសវនាការ នឹង បានផ្ញើទៅឲ្យអ្នក ។ អ្នកអាចសួរសំណួរអំពីពត៌មានដែលគេបង្ហាញ ហើយអ្នកក៏អាចពន្យល់ពីមូលហេតុដែលអ្នកយល់ថាការសំរេចនោះគឺមិនត្រឹមត្រូវទេ ។ អ្នកក៏អាច ពិភាក្សាអំពីសំភារៈ(សំបុត្រស្នាម) និងពត៌មានទាំងអស់ដែលបានបង្ហាញផងដែរ ។

**សេចក្តីសង្ខេបការសំរេច** – បន្ទាប់ពីអ្នកស្នើសុំតវ៉ាមក នោះអ្នក ឬ ASAP អាចស្នើយកសេចក្តីសង្ខេបនៃការសំរេច ដោយទាក់ទង (អ្នកសំរបសំរួលសវនាការ កិច្ច ការចាស់ទុំ) Elder Affairs Hearing Coordinator តាមលេខ 617-727-7750 ។ សេចក្តីសង្ខេបការសំរេចគឺមានន័យថា អ្នកយល់ស្របជាមួយ ASAP អំពីដំណើរហេតុនៃរឿងរ៉ាវរបស់អ្នក ហើយអ្នកមិនចង់ធ្វើសវនាការតាមទូរស័ព្ទ ឬដោយផ្ទាល់មុខទេ ប៉ុន្តែអ្នកនៅតែចង់សុំតវ៉ានឹងការសំរេចនៃ ASAP ទៀត ។ បើសិន ជាសំណើរបស់អ្នកបានអនុញ្ញាត នោះនាយកសវនាការនឹងមើលតែពត៌មានដែលបានសរសេរ ដែលអ្នក និង ASAP បានបញ្ជូនមក រួចក៏ធ្វើការសំរេច ។

នៅក្នុងរយៈពេលកៅសិប (90) ថ្ងៃនៃប្រក្រតិទិន នៃថ្ងៃសវនាការរបស់អ្នក ឬថ្ងៃបានបញ្ជូនឯកសារមានចុះហត្ថលេខា សំរាប់សេចក្តីសង្ខេបការសំរេច នោះនាយកសវនា ការនឹងរៀបចំការសំរេចជាលាយល័ក្ខអក្សរ ។ ការិយាល័យកិច្ចការចាស់ទុំ នឹងផ្ញើច្បាប់ចំឡងនៃការសំរេចទៅឲ្យអ្នក និង ASAP ដោយមានសេចក្តីពន្យល់ណែនាំអំពី របៀបដែលអ្នកអាចសុំតវ៉ារឿងរ៉ាវទៅថ្នាក់លើទៀត ។ សវនាការ និងសេចក្តីសង្ខេបការសំរេចគឺចាប់មានប្រសិទ្ធិភាពនៅពេលអ្នកបានទទួលដំណឹងនៃការសំរេច ។

បើអ្នកមានបំណងចង់សុំតវ៉ា អ្នកត្រូវតែផ្ញើសំណើដែលមានភ្ជាប់មកជាមួយ ទៅការិយាល័យកិច្ចការចាស់ទុំ ក្នុងរយៈពេលសាមសិប (30) ថ្ងៃនៃប្រក្រតិទិន ចាប់តាំងពីថ្ងៃ អ្នកបានទទួលការសំរេចពីការពិនិត្យមើលឡើងវិញនៃ ASAP មក ។ បើអ្នកពុំផ្ញើសំណើរសំរាប់ការស្នើសុំតវ៉ាក្នុងរយៈពេលសាមសិបថ្ងៃនៃប្រក្រតិទិនទេ អ្នកនឹងបាត់ បង់សិទ្ធិរបស់អ្នកដើម្បីសុំតវ៉ាហើយ ។